មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៦-៦-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៦៨ ស្ដីពីការតែងតាំងឯកឧត្ដម **តែ ណារុន** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើអគ្គនាយក ១១៦១

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១៤-៦-២០០៤ -អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន ១១៦២

១៦-៦-២០០៤ -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្ដីពីការប្រើប្រាស់គហេនីឯកជនភារូបនីយកម្មសហគ្រាសសាធារណៈ ១១៦៦

១៦-៦-២០០៤ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ១១៦៨

១៦-៦-២០០៤ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ១១៦៩

១៧-៦-២០០៤ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ១១៧០

១៧-៦-២០០៤ -អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ១១៧១

១៧-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ១១៧៦

១៧-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៤ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ១១៨១

២១-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៥អនក្រ.តតស្ដីពីការតម្លើងឋានន្តរសក្តិនាយទាហានបាលជាតិជាកិច្ចបច្ឆាមរណៈ ១១៨២

២២-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ១១៨៣

២២-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ១១៨៥

២២-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ១១៨៦

២២-៦-២០០៤ -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ១១៨៨

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១១៨៩

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១១៩០

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្ដីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ១១៩១

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្ដីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ១១៩២

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១១៩៣

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ១១៩៤

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្ដីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ១១៩៥

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ១១៩៦

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១១៩៧

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៨

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១៩៩

២៣-៦-២០០៤ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២០០

២.សេចក្តីសំរេច

២២-៦-២០០៤ -សេចក្តីសំរេចលេខ ៣៧ សសរ ស្តីពីការបង្កើតឡើងនូវក្រុមការងារចំរុះមួយ រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយនឹងក្រុមហ៊ុន Chevron Overseas Petroleum Limited ព្រមទាំងក្រុមហ៊ុនដៃគូ និងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សារួមគ្នារៀបចំអោយមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់ឧស្ម័នធម្មជាតិ ពីប្លុក A វៃដនសមុទ្រកម្ពុជា ១២០១

៣.បទបញ្ជា

២៣-៦-២០០៤ -បទបញ្ជាលេខ ០២ បប ស្តីពីការទប់ស្កាត់ និងលុបបំបាត់អំពើអនាធិបតេយ្យ នៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប ១២០៤

III.ការងារបណ្តាក្រសួង

១.អន្តរក្រសួង ក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ

២៣-៦-២០០៤ -ប្រកាសអន្តរក្រសួងលេខ ២២១ បក.សកក អជ ស្តីពីការកំរិតកំណត់ទំងន់អតិបរិមានៃរថយន្តដឹកជញ្ជូនផ្លូវគោកដែល បើកបរលើបណ្តាញផ្លូវខេត្ត និង ផ្លូវជនបទ នៃព្រះរាជាណាចក្រ កម្ពុជា ១២០៧

២. ក្រសួងអប់រំ យុវជន និង កីឡា

២៣-៦-២០០៤ -ប្រកាសលេខ ៦៧២ អយក.ប្រក ស្តីពីការកំណត់មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ១២៣១

ព្រះរាជក្រឹត្យ

នស/រកត/០៦០៤/១៧៨

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម ខៃ ឈានុន ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើអគ្គនាយក ។

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះរាជវាំងភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្ដីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

ជ.រ.ស. ០៤.០៦.០៩៨
លេខ : ៧៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ប្រាក់ សុខុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ...៦៧... អនក្រ - បក

អនុក្រឹត្យ

ស្តីពី

ការកែសំរួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ។
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៩៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សំរេច

មាត្រា១ៈ

កែសំរួលមាត្រា ២៥ មាត្រា ៤០ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៧ មាត្រា ៥១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន

និងមាត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដូចខាងក្រោម :

មាត្រា២៥ថ្មី ..

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំសំបុត្រកំណើតនេះពី មេឃុំ ចៅសង្កាត់ សាមី ដោយបង់ប្រាក់ថ្លៃសំបុត្រកំណើតដល់អាជ្ញាធរ ឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀលសំរាប់ប្រជាពលរដ្ឋមានទីលំនៅនៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែមអំពីបែបបទ និង នីតិវិធីនៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងករណីខាងលើនេះ ។

មាត្រា៤០ថ្មី ..

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែម អំពីបែបបទ នីតិវិធី នៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងករណីខាងលើនេះ ។

មាត្រា៤៣ថ្មី ..

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅ សាលាឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សី ចំនួន ០២ រូប ជាមិត្តជិតជន ហើយត្រូវមានទីលំនៅពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខ មន្ត្រីអត្រា-នុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវអោយខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

មាត្រា៤៥ថ្មី ..

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍-ពិពាហ៍ សាមីខ្លួនទាំងពីររូបអាចសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជន និងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

មាត្រា៤៧ថ្មី ..

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តាន ដែលនៅរស់អាចមកសុំចុះ សៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មី នៅសាលា ឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សី ចំនួន ០២ រូប ជានីតិជន ហើយមានទីលំនៅពិតប្រាកដ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

មាត្រា៥១ថ្មី ..

ការសុំចម្លង ឬ សំរង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំត្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឬសង្កាត់ ហើយត្រូវបោះត្រាផង ។

មាត្រា៥៩ថ្មីស្ទួន ..

ក. ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យនេះ ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តីឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់បញ្ជីត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅ ត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

២.ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ប្រជាពលរដ្ឋ ដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានរួចមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៥ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែលឪពុកឬម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលក្នុងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នោះនឹងត្រូវបាន ផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

៣.ដើម្បីបង្កលក្ខណៈសម្បត្តិងាយស្រួល ជូនប្រជាពលរដ្ឋ ក្នុងការចុះសៀវភៅអត្រា-នុកូលដ្ឋាន ឃុំ សង្កាត់ អាចចាត់អោយមានការចុះសៀវភៅអត្រានុកូលដ្ឋានចល័តក្នុងឃុំ សង្កាត់របស់ខ្លួនតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ ។

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រើប្រាស់គណនី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

***

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០៣
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៨ ស្តីពីបេសកកម្ម នៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ...

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រើប្រាស់គណនី "ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ" ដែលត្រូវបានបង្កើតឡើង តាមមាត្រា ៨៣ នៃ ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ លើមុខសញ្ញាចំណាយសំរាប់ផ្តល់ថវិកាបដិភាគជូនសាលាក្រុងភ្នំពេញចំណាយទិញដី ទំហំ ១៩៦.៨៧៩ ម៉ែ ក្នុងខ័ណ្ឌដង្កោ ដើម្បីសាងសង់ទីលានចាក់សំរាមថ្មី នៃគំរោងគ្រប់គ្រងកាកសំណល់រឹងក្នុងរាជធានីភ្នំពេញ ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនដែលមានតំលៃទឹកប្រាក់សរុប ចំនួន **USD 688.213,00** (ប្រាំមួយរយប៉ែតសិបប្រាំបីពាន់ពីររយដប់បី ដុល្លារអាមេរិក) ។

មាត្រា ២ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សាលាក្រុងភ្នំពេញ និង ប្រធានស្ថាប័ន ដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៦ ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៣៣៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៦រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលនានា ដូចជាព្រះវិហារ កុដិ សាលាធម្មសភា និង របង នៅវត្តអង្គថ្មី ឃុំសិង្ហ ស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**គឹម សារឿន**	ចៅអធិការវត្តអង្គថ្មី	បច្ច័យចំនួន ១២.៥០០ ដុល្លារ
២-ឧបាសិកា	**ឡុង កាន់**	នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២៥.៧២៣ ដុល្លារ

ខ. មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសក	**ញ៉ឹម ឆេន**	នៅខេត្តតាកែវ	ថវិកាចំនួន ៥.២៥០ ដុល្លារ
២-ឧបាសក	**អន ឃេង**	នៅខេត្ត តាកែវ	ថវិកាចំនួន ៥.១១៥ ដុល្លារ
៣-ឧបាសក	**វ៉ៀង នុយ**	នៅខេត្ត តាកែវ	ថវិកាចំនួន ៥.១០០ ដុល្លារ
៤-ឧបាសក	**ឡូ ខ៊ាន់**	នៅខេត្ត តាកែវ	ថវិកាចំនួន ៥.០៥០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ជប៉ុន ចំនួន ០២រូប ដែលបានផ្តល់ថវិកា ចំនួន ៤៦.១៥៨.២៨ ដុល្លារ សំរាប់ជួយកសាងអគារសិក្សា ០១ខ្នង បង្គន់អនាម័យ ០១ខ្នង និងអណ្តូងទឹកស្អាត ០១ ដោយមានបំពាក់នូវសម្ភារឹមគ្រប់គ្រាន់ ជូនសាលាបឋមសិក្សា វិហារខ្ពស់ ស្ថិតក្នុងឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :

-លោក SHIMASU YOSHIO តំណាងសមាគម ឡាយអុនគ្លិប ខេត្តជីបា

-លោក MATSUI MICHIO តំណាងសមាគម ឡាយអុនគ្លិប ខេត្តជីបា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤១ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយសុវត្ថារា

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្ដាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់ចំនួន ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក.-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ

ឯកឧត្តម **ទេព ងន** សមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

ខ.-មេដាយសុវត្ថារា ថ្នាក់ សេនា

១ ឯកឧត្តម **លឹម លាងសែ** នាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
២ ឯកឧត្តម **ង៉ែ ម៉ិនឈឿន** ទីប្រឹក្សាផ្ទាល់សម្ដេចប្រធានព្រឹទ្ធសភា
៣ ឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
៤-ឯកឧត្តម **ប្រាក់ វណ្ណឌី** នាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី
ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៤៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
បានឃើញព្រះរាជក្រមលេខ ០.៣ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
តាមសំណើរបស់អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនឯកឧត្តម , លោកជំទាវ អស់លោក លោកស្រី ជាមន្ត្រីរាជការចំនួន ១០៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម ÷

ក.មេដាយមាសការងារ :

១ ឯកឧត្តម ស៊ាន បូរ៉ាត ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី
២ ឯកឧត្តម យី-ជន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី
៣-ឯកឧត្តម ស្រី ថាមរុង្គ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី
៤-ឯកឧត្តម ហៅ-តុល ជំនួយការសម្តេចនាយករដ្ឋមន្ត្រី
៥ ឯកឧត្តម សេង ទៀង ជំនួយការសម្តេចនាយករដ្ឋមន្ត្រី
៦ ឯកឧត្តម គីម ប៊ុនថាន នាយករងខុទ្ទកាល័យអគ្គមេបញ្ជាការ
៧-លោកឧកញ៉ា ស៊ីវ ផៃ នាយកក្រុមហ៊ុន OMC
៨ លោក ផៃ នរសត្យា អគ្គនាយកវិទ្យុ ទូរទស្សន៍បាយ៉ន

៩ លោក ទី សុគន្ធ	ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់
១០-លោក មាស-សឿន	ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តកណ្ដាល
១១-លោក ចាប-ម៉ុច	ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្ដាល
១២-លោក ហេង-ស្រួយ	មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តកណ្ដាល
១៣-លោក ទុយ-ច័ន្ទផល្លីន	អនុប្រធានមន្ទីរអប់រំយុវជននិងកីឡាខេត្តកណ្ដាល
១៤-លោកស្រី នួន-នារតី	នាយិកាមជ្ឈមណ្ឌលគរកោសល្យភូមិភាគខេត្តកណ្ដាល
១៥ លោក ហាក់ ចាន់រឿន	វេជ្ជបណ្ឌិតមន្ទីរពេទ្យកាល់ម៉ែត្រ
១៦ លោក ស៊ុយ ឈុនហាក់	នាយរងទី១ លេខាធិការដ្ឋានមេធាវី រាជរដ្ឋាភិបាល
១៧ លោក ឡាយ ប៊ូរិន	អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងអប់រំយុវជន និង កីឡា
១៨ លោក គុល គឹមលី	អនុប្រធាននាយកដ្ឋានស្ថាបនាក្រសួងមហាផ្ទៃ
១៩ លោក អឹម-ពៅ	មន្ត្រីអាជ្ញាធរប្រេងកាតនៃទីស្ដីការគណៈរដ្ឋមន្ត្រី
២០ លោក ជួន ជីរិន	និស្សិតថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់រាជបណ្ឌិតសភាកម្ពុជា
២១ លោក វ៉ាន់-ប៊ុនថេត	នាយករងសាលាភូមិន្ទរដ្ឋបាល
២២ លោក សុខ-ធារ៉ុធ	មន្ត្រីនាយកដ្ឋានបុគ្គលិក ទីស្ដីការគណៈរដ្ឋមន្ត្រី
២៣ លោក ឈាង ផាន់ណារិទ្ធ	មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
២៤ លោក អ៊ុយ សារិន	មន្ត្រីគយនិងរដ្ឋាករ (ការិយាល័យត្រួតពិនិត្យ)
២៥ លោក គីម សម្បុក	មន្ត្រីសាលាខេត្តកណ្ដាល
២៦ លោក ម៉ែន-សុភារ៉ុធ	មន្ត្រីសាលាខេត្តកណ្ដាល
២៧ លោក អ៊ុក-ជី	មន្ត្រីសាលាខេត្តកណ្ដាល
២៨-លោក រុន-ធុល	មន្ត្រីសាលាខេត្តកណ្ដាល
២៩ លោក ជុំ-ជួន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកណ្ដាល
៣០-លោក សាំង-យ៉ង	អភិបាលរងស្រុកស្អាង ខេត្តកណ្ដាល
៣១-លោក វរៈសេនីយ៍ត្រី ហង់-ជួនវឌ្ឍនា	ពេទ្យអង្គរក្សសម្ដេចនាយករដ្ឋមន្ត្រី
៣២ លោក ទិត ដា	មន្ត្រីគយនិងរដ្ឋាករ (ការិយាល័យត្រួតពិនិត្យ)
៣៣-លោក អួន រស្មី	អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តកណ្ដាល
៣៤-លោក ខិម-ច័ន្ទតីរ៍	អភិបាលស្រុកស្អាង ខេត្តកណ្ដាល
៣៥-លោក សុខ-ប៊ិនស៊ុន	អភិបាលរងស្រុកស្អាង ខេត្តកណ្ដាល
៣៦ លោក ព្រុំ-ឈឺន	អនុប្រធានមន្ទីរស្រុកស្អាង ខេត្តកណ្ដាល

៣៧ លោក សួស-សម្បត្តិ មន្ត្រីក្រសួងពាណិជ្ជកម្ម

៣៨ លោក ស៊ត-តារា មន្ត្រីក្រសួងពាណិជ្ជកម្ម

៣៩-លោក អ៊ិត ហុង អនុប្រធានការិយាល័យសុរិយោដីនិងភូមិបាលស្រុកស្អាងខេត្តកណ្ដាល

៤០-លោក ជ៉ាន់ ងួន ប្រធានការិយាល័យសុរិយោដីនិងភូមិបាលស្រុកស្អាងខេត្តកណ្ដាល

៤១-លោក ខឿក សេងហាក ប្រធានការិយាល័យសាធារណការស្រុកស្អាង ខេត្តកណ្ដាល

៤២ លោកស្រី យឹម យុត្តិរី ប្រធានមន្ទីរស្រុកស្អាង ខេត្តកណ្ដាល

៤៣ លោក យី ប៊ុយ មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្ដាល

៤៤ លោកស្រី ឡៅ វណ្ណារ័ត្ន ប្រធានការិយាល័យកិច្ចការនារីស្រុកស្អាង ខេត្តកណ្ដាល

៤៥ លោក នូ ស៊ីផាត ប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្ដាល

៤៦ លោក នុង-ហុក ប្រធានការិយាល័យកសិកម្មស្រុកស្អាង ខេត្តកណ្ដាល

៤៧-លោក ម៉ុក-ប៊ុនធឿន ប្រធានការិយាល័យព័ត៌មានស្រុកស្អាង ខេត្តកណ្ដាល

៤៨-លោក អួន សឿន ប្រធានការិយាល័យធម្មការនិងកិច្ចសាសនាស្រុកស្អាង ខេត្តកណ្ដាល

៤៩-លោក អ៊ុំ-ពួន ប្រធានការិយាល័យសុខាភិបាលស្រុកស្អាង ខេត្តកណ្ដាល

៥០ លោក ឈី គង់ នាយកវិទ្យាល័យ ហ៊ុន-សែន ស្អាង ខេត្តកណ្ដាល

៥១ លោក អ៊ុង-ថាវី មេបញ្ជាការកងរាជអាវុធហត្ថស្រុកស្អាង ខេត្តកណ្ដាល

៥២-លោក លន់-សុផាត អធិការនគរបាលស្រុកស្អាង ខេត្តកណ្ដាល

៥៣-លោក ដា ផល មេបញ្ជាការផ្នែកសឹករងស្រុកស្អាង ខេត្តកណ្ដាល

៥៤-លោក ទួន-ច័ន្ទរិទ្ធ ប្រធានការិយាល័យនាំចេញនៃទីស្នាក់ការគយ និងរដ្ឋាករ

ខ-មេដាយប្រាក់ការងារ :

១ លោក អាត់-សំអាត មន្ត្រីសាលាខេត្តកណ្ដាល

២-លោក ភឿក ណយ មន្ត្រីសាលាខេត្តកណ្ដាល

៣ លោក ឆុន-ស៊ីដេត មន្ត្រីសាលាខេត្តកណ្ដាល

៤-លោក អ៊ឹម សជុន មន្ត្រីសាលាខេត្តកណ្ដាល

៥-លោក សូ ជាន់ណារិទ្ធ មន្ត្រីសាលាខេត្តកណ្ដាល

៦ លោក ជូ-មន មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្ដាល

៧ លោក អួយ-ប៊ុនធឿន មេបញ្ជាការរងផ្នែកសឹករងស្រុកស្អាង ខេត្តកណ្ដាល

៨ លោក អួន-សន មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកស្អាង ខេត្តកណ្ដាល

៩ លោក វ័ត្ត រិទ្ធី	អធិការរងនគរបាលស្រុកស្អាង ខេត្តកណ្តាល
១០ លោក កែវ សារិន	អនុប្រធានការិយាល័យបសុពេទ្យ ... ស្រុកស្អាង ខេត្តកណ្តាល
១១ លោក អ៊ុំ សាមុត	ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកស្អាង ខេត្តកណ្តាល
១២ លោក លឹម សំលៀ	គ្រូវិទ្យាល័យហ៊ុន សែន ស្អាង ខេត្តកណ្តាល
១៣ លោកស្រី អ៊ួន-ឆេង	ប្រធានការិយាល័យវប្បធម៌និងវិចិត្រសិល្បៈស្រុកស្អាង ខេត្តកណ្តាល
១៤ លោក ឃុន-លីមហេង	ប្រធានការិយាល័យសេដ្ឋកិច្ចរោងចក្រស្រុកស្អាង ខេត្តកណ្តាល
១៥ លោក ជួន ហ៊ាង	មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្តាល
១៦-លោក ប៊ុត-រ័កែវ	ប្រធានការិយាល័យសង្គមកិច្ចការងារស្រុកស្អាង ខេត្តកណ្តាល
១៧ លោកស្រី វស់ ស៊ីរ៉ែន	មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្តាល
១៨ លោក ឃាម-វ៉េងអ៊ាង	អនុប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
១៩ លោក កែម តាំង	មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្តាល
២០ លោក លឹម សផល	អធិការរងនគរបាលស្រុកស្អាង ខេត្តកណ្តាល
២១ លោក ជា-គង់	មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្តាល
២២ លោក ព្រាប ហាន់ថូ	អនុប្រធានផ្នែកសន្តិសុខនគរបាលស្រុកស្អាង ខេត្តកណ្តាល
២៣ លោក អ៊ុយ សៅ	អនុប្រធានការិយាល័យសេដ្ឋកិច្ចសាលាស្រុកស្អាង ខេត្តកណ្តាល
២៤ លោក សែម ហាន់ផន	អនុប្រធានការិយាល័យសាធារណការស្រុកស្អាង ខេត្តកណ្តាល
២៥ លោក តេ តុយ	អនុប្រធានការិយាល័យបរិស្ថានស្រុកស្អាង ខេត្តកណ្តាល
២៦ លោក អ៊ូ ជាតន្ទ	អនុប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
២៧-លោក ប៊ុន-ច័ន្ទផល	នាយកសាលាបឋមសិក្សាពោធិវង្ស ស្រុកស្អាង ខេត្តកណ្តាល
២៨ លោក អ៊ិន សារ៉ុធ	អធិការរងនគរបាលស្រុកស្អាង ខេត្តកណ្តាល
២៩ លោក យូ វ៉ាន់ថា	ប្រធានការិយាល័យស្ថិតិ ផែនការស្រុកស្អាង ខេត្តកណ្តាល
៣០ លោក សាត សន	អនុប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
៣១ លោក សែម សុខ	ប្រធានផ្នែកសរុបរដ្ឋបាលអធិការដ្ឋាននគរបាលស្រុកស្អាង ខេត្តកណ្តាល
៣២ លោក វ៉ង់ ប៊ុន	អនុប្រធានការិយាល័យសង្គមកិច្ចការងារស្រុកស្អាង ខេត្តកណ្តាល

គ-មេដាយសេរីវឌ្ឍនភាពសំរឹទ្ធ :

១ លោក ប៊ិន-រស៊ី	មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
២ លោកស្រី សែម ច័ន្ទធូ	អនុប្រធានការិយាល័យសង្គមកិច្ចសាលាស្រុកស្អាង ខេត្តកណ្តាល
៣-កញ្ញា ឡុក-សខា	មន្ត្រីការិយាល័យព័ត៌មានស្រុកស្អាង ខេត្តកណ្តាល

៤-លោកស្រី សារ៉េត សារី	មន្ត្រីសាលាខេត្តកណ្តាល
៥ លោកស្រី ផាន់ ខាន់	មន្ត្រីសាលាខេត្តកណ្តាល
៦-លោក ឡាយ-សុផល	អនុប្រធានការិយាល័យស្ថិតិផែនការស្រុកស្អាង ខេត្តកណ្តាល
៧-លោក អ៊ុក សុគន្ធ	អនុប្រធានការិយាល័យកសិកម្មស្រុកស្អាង ខេត្តកណ្តាល
៨-លោក សយ-សារវុទ្ធ	ប្រធានផ្នែកភស្តុភារនគរបាលស្រុកស្អាង ខេត្តកណ្តាល
៩-លោក សិត ខឿន	មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
១០ លោក ឈីវ-ហុក	មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
១១-លោក ស្រ៊ីវ-គឹម	មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
១២-លោក គង្គ-គឹមយ៉ន	ប្រធានការិយាល័យរដ្ឋបាលសាលាស្រុកស្អាង ខេត្តកណ្តាល
១៣-លោក តុប-លី	មន្ត្រីការិយាល័យកសិកម្មស្រុកស្អាង ខេត្តកណ្តាល
១៤ លោក តា វណ្ណារិទ្ធ	មន្ត្រីការិយាល័យអប់រំយុវជននិងកីឡាស្រុកស្អាង ខេត្តកណ្តាល
១៥-លោក សួន-សាម	អនុប្រធានផ្នែកពន្ធដារស្រុកស្អាង ខេត្តកណ្តាល
១៦ លោក យស ប៊ុនថន	មន្ត្រីការិយាល័យពត៌មានស្រុកស្អាង ខេត្តកណ្តាល
១៧-លោក សុខ វឿន	មន្ត្រីសាលាស្រុកស្អាង ខេត្តកណ្តាល
១៨-លោក អ៊ិន-គួ	អនុប្រធានការិយាល័យវប្បធម៌និងវិចិត្រសិល្បៈស្រុកស្អាងខេត្តកណ្តាល
១៩-លោក សួន-កៅ	ប្រធានការិយាល័យបរិស្ថានស្រុកស្អាង ខេត្តកណ្តាល

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និង មាត្រា២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

&&&&&

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម , លោកជំទាវ អស់លោក លោកស្រី ជាមន្ត្រីរាជការចំនួន ១៤០ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក.មេដាយមាសការងារ :

១-ឯកឧត្តម ម៉ុម - ជឹមហ៊ុយ	តំណាងរាស្ត្រមណ្ឌលកណ្តាល
២-ឯកឧត្តម គន់ - គីម	អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ
៣-ឯកឧត្តម ប្រាជ្ញ ស៊ុន	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន
៤- ឯកឧត្តម សយ- ស៊ីផុន	អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ
៥-ឯកឧត្តម សួន - សិទ្ធី	អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា
៦- ឯកឧត្តម ស៊ុម - មាន	ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី
៧- ឯកឧត្តម រស់ - រ៉េន	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍
៨-ឯកឧត្តម រស់ - វណ្ណា	អគ្គនាយកភ្នាក់ងារនាវាចរកម្ពុជា
៩ ឯកឧត្តម ស៊ូ គឹមស៊ុន	ទីប្រឹក្សាអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
១០ ឯកឧត្តម សែម សុវណ្ណនី	មេបញ្ជាការរងបញ្ជាការវិស្វកម្ម
១១-ឯកឧត្តម ពៅ - ផារី	មេបញ្ជាការរងបញ្ជាការវិស្វកម្ម

១២ ឯកឧត្តម កោប កក្ដី មេបញ្ជាការកងពលតូចឆ័ត្រយោង ៩១១

១៣-ឯកឧត្តម តូច ចាន់កសល អគ្គនាយករងទី ១នៃអគ្គនាយកដ្ឋានសាធារណការ

១៤ ឯកឧត្តម ឡេង-ធនយុទ្ធា អគ្គនាយកដឹកជញ្ជូន នៃក្រសួងសាធារណការ និង ដឹកជញ្ជូន

១៥ ឯកឧត្តម ស្លួត -សំបូរ អគ្គនាយករដ្ឋបាល នៃក្រសួងសាធារណការ

១៦ លោក រ៉ាស៊ីម- សុរិយា ប្រធាននាយកដ្ឋានកិច្ចការ [illegible] នៃក្រសួងសាធារណការ

១៧ ឯកឧត្តម សួន រចនា ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

១៨ ឯកឧត្តម ប៊ុន សំបូរ ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី

១៩ លោក ម៉ែន វណ្ណមុនី នាយសេនាធិការរងកងពល តូចលេខ ៧០

២០-លោក កែវ - សារ៉ាន់ មេបញ្ជាការរងកងពលតូចវិស្វកម្មលេខ ៧៥

២១ លោក សោម -សុវុឌ្ឍី ទីប្រឹក្សា ឯកឧត្តម គន់ គីម

២២ លោក ដួង - សារិន នាយកសាលាកងរាជអាវុធហត្ថជាតិ

២៣ លោក លឹម សីដេនីន នាយកនៃនាយកដ្ឋានស្ពានថ្នល់

២៤ លោក ចាន់ តារា នាយកនៃនាយកដ្ឋាននាវាចរណ៍ឆ្នេរសមុទ្រ

២៥ លោក ម្រេច ប៉ាង ប្រធានអង្គភាពផ្លូវថ្នល់ នៃនាយកដ្ឋានផ្លូវថ្នល់

២៦ លោក សរ ស៊ីផន នាយករងមជ្ឈមណ្ឌលគ្រឿងចក្រធំ ៧

២៧ លោក ស្ដើង ជា ប្រធានការិយាល័យរដ្ឋបាល មន្ទីរពេទ្យកុមារជាតិ

២៨ លោក ទូច ផុន ប្រធានមន្ទីរសង្គមកិច្ចការងារ ខេត្តកណ្ដាល

២៩ លោកស្រី ប៊ុន ពុទ្ធី អនុប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្តកណ្ដាល

៣០ លោក សន ផេន ស្នងការរងនគរបាលខេត្តកណ្ដាល

៣១ លោកស្រី ប្រាក់ សារ៉ាង អនុប្រធានមន្ទីរ [illegible] និង [illegible]
មណ្ឌលកុមារកំព្រា [illegible]

៣២-លោក អ៊ូ - សំអូន អភិបាលស្រុកអង្គស្នួល ខេត្តកណ្ដាល

៣៣ លោក អ៊ឹម សាក់ ជំនួយការឯកឧត្តម អភិបាលរងទី ១ ខេត្តកណ្ដាល

៣៤-លោក អ៊ិន - ឃុន អភិបាលរងស្រុកអង្គស្នួល ខេត្តកណ្ដាល

៣៥-លោក ឈុន-សុភាព អភិបាលរងស្រុកអង្គស្នួល ខេត្តកណ្ដាល

៣៦ លោក ជុំ សជាតិ ប្រធានមន្ទីរស្រុកអង្គស្នួល ខេត្តកណ្ដាល

៣៧-លោក យ៉ឹម - វីរុទ្ធ អនុប្រធានមន្ទីរស្រុកអង្គស្នួល ខេត្តកណ្ដាល

៣៨-លោក មិន - ភី ប្រធានការិយាល័យសេដ្ឋកិច្ចសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល

៣៩ លោក ប្រេស-សារុំ ប្រធានការិយាល័យ កសិកម្មស្រុកអង្គស្នួល ខេត្តកណ្ដាល

៤០ លោក ហឹម ហ៊ុម ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកអង្គស្នួល ខេត្តកណ្ដាល

៤១ លោក សខ ចំរើន អនុប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកអង្គស្នួលខេត្តកណ្ដាល

៤២-លោក អ៊ិក -សឿង ប្រធានការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈ ស្រុកអង្គស្នួលខេត្តកណ្ដាល

៤៣-លោក ទឹង- វុទ្ធី អនុប្រធានការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈស្រុកអង្គស្នួលខេត្តកណ្ដាល

៤៤ លោក ឈុន សារិន ប្រធានការិយាល័យធនាគារស្រុកអង្គស្នួល ខេត្តកណ្ដាល

៤៥ លោក ម៉ៅ សុខ ប្រធានការិយាល័យបរិស្ថានស្រុកអង្គស្នួល ខេត្តកណ្ដាល

៤៦ លោក ប៉ែន - សេដ្ឋា ប្រធានការិយាល័យ [illegible] ស្រុកអង្គស្នួល ខេត្តកណ្ដាល

៤៧-លោក មិញ - គឹមសាន អនុប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកអង្គស្នួល ខេត្តកណ្ដាល
៤៨-លោក ប្រាក់ - សុខន មន្ត្រីការិយាល័យអប់រំស្រុកអង្គស្នួល ខេត្តកណ្ដាល
៤៩-លោក គួយ - សេង ប្រធានការិយាល័យហិរញ្ញវត្ថុស្រុកអង្គស្នួល ខេត្តកណ្ដាល
៥០ លោក លៀង ហុង ប្រធានការិយាល័យកិច្ចការនារីស្រុកអង្គស្នួល ខេត្តកណ្ដាល
៥១ លោក ឈិត រហេង ប្រធានការិយាល័យសាធារណការស្រុកអង្គស្នួល ខេត្តកណ្ដាល
៥២-លោក កែម សុផាវី្ញ ប្រធានការិយាល័យការងារ [illegible] និង [illegible]ពលស្រុកអង្គស្នួលខេត្តកណ្ដាល
៥៣ លោក ពិន - កែវណារិទ្ធិ បញ្ជាការរងផ្នែកសីករជស្រុកអង្គស្នួល ខេត្តកណ្ដាល
៥៤ លោក សួង យ៉ាន់ អនុប្រធានការិយាល័យចរាចរណ៍ជើងទឹក នគរបាលខេត្តកណ្ដាល
៥៥-លោក ខៀវ - ឃិន មន្ត្រីសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល

ខ-មេដាយប្រាក់ការងារ :

១-លោកស្រី យិន សុខន ប្រធានការិយាល័យរដ្ឋបាលសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល
២-កញ្ញា កែវ ណារ៉េត អនុប្រធានការិយាល័យរដ្ឋបាលសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល
៣-លោក សរ វ៉េង អនុប្រធានការិយាល័យសង្គមកិច្ច សាលាស្រុកអង្គស្នួល ខេត្តកណ្ដាល
៤ លោក សោម ឯល មន្ត្រីសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល
៥ លោក អៀង - ថៃម មន្ត្រីសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល
៦ លោកស្រី សុខ -វណ្ណថល មន្ត្រីការិយាល័យអប់រំយុវជន និងកីឡា ស្រុកអង្គស្នួលខេត្តកណ្ដាល
៧ លោក ហេង ចិន្ដា អធិការរងនគរបាលស្រុកអង្គស្នួល ខេត្តកណ្ដាល
៨ លោក រិន - យឹន ប្រធានការិយាល័យធនធានទឹកស្រុកអង្គស្នួល ខេត្តកណ្ដាល
៩ លោក ឯម - បៃ មន្ត្រីការិយាល័យធនាគារស្រុកអង្គស្នួល ខេត្តកណ្ដាល
១០ លោក ថន ណារ៉ា អធិការរងនគរបាលស្រុកអង្គស្នួល ខេត្តកណ្ដាល
១១-លោក ថោង សំអន នាយអនុវិទ្យាល័យត្រពាំងត្នោតស្រុកអង្គស្នួល ខេត្តកណ្ដាល
១២-លោក ជ័យ ជួរ អនុប្រធានពន្ធដារស្រុកអង្គស្នួល ខេត្តកណ្ដាល
១៣ លោក ម៉ុក - ប៊ិច ប្រធានការិយាល័យ ពត៌មានស្រុកអង្គស្នួល ខេត្តកណ្ដាល
១៤ លោក សុខ ស៊ុនអេង មន្ត្រីការិយាល័យ ហិរញ្ញវត្ថុស្រុកអង្គស្នួល ខេត្តកណ្ដាល
១៥ លោកស្រី សោម-ប៊ុណ្ណា ប្រធានការិយាល័យផែនការស្រុកអង្គស្នួល ខេត្តកណ្ដាល
១៦-លោក កង យ៉ុន គ្រូវិទ្យាល័យ ហ៊ុន សែន អង្គស្នួល
១៧ លោក លី - វិឡានា អនុប្រធានការិយាល័យរៀបចំដែនដី ភូមិបាលស្រុក អង្គស្នួល ខេត្តកណ្ដាល
១៨ លោក ចេង ណាំ អនុប្រធានការិយាល័យកសិកម្មស្រុកអង្គស្នួល ខេត្តកណ្ដាល
១៩ លោក ផង់ ហ៊ល ប្រធានការិយាល័យពាណិជ្ជកម្មស្រុកអង្គស្នួល ខេត្តកណ្ដាល
២០ លោក លាវ គឹមសល់ មន្ត្រីការិយាល័យអប់រំយុវជន និងកីឡា ស្រុកអង្គស្នួល ខេត្តកណ្ដាល
២១ លោក ស៊ក អុល នាយករងអនុវិទ្យាល័យបឹងធំស្រុកអង្គស្នួល ខេត្តកណ្ដាល
២២-លោក ប៊ួយ ប៊ូរី អនុប្រធានការិយាល័យអប់រំស្រុកអង្គស្នួល ខេត្តកណ្ដាល
២៣-លោក គីម សុគន្ធ អធិការរងនគរបាលស្រុកអង្គស្នួល ខេត្តកណ្ដាល
២៤ លោក គុជ សុធា អនុប្រធានការិយាល័យសង្គមកិច្ចស្រុកអង្គស្នួល ខេត្តកណ្ដាល
២៥-លោក ហង ឈំ នាយកវិទ្យាល័យ ហ៊ុន សែន អង្គស្នួល
២៦ លោក មៀន- សាម៉ុន នាយកសាលាបឋមសិក្សាកយគីបស្រុក អង្គស្នួល ខេត្តកណ្ដាល

២៧ លោក ញឹប - លី នាយកអនុវិទ្យាល័យ បែកចានស្រុកអង្គស្នួល ខេត្តកណ្តាល

២៨-លោក អ៊ឹង - ចំរ៉ុង នាយករងវិទ្យាល័យ ហ៊ុន សែន អង្គស្នួល

២៩ លោក ឈឹម - សុផល គ្រូវិទ្យាល័យ ហ៊ុន សែន អង្គស្នួល

៣០-លោក សោម- វ៉ាន់ថៃ មន្ត្រីមន្ទីរសង្គមកិច្ចការងារខេត្តកណ្តាល

៣១ លោក ហង់ សាម៉ន នាយកវិទ្យាល័យ ទាន់អរ ស្រុកអង្គស្នួល ខេត្តកណ្តាល

៣២-លោក ឯក - សំអុល នាយកសាលាបឋមសិក្សា សុព័រស្រុកអង្គស្នួល ខេត្តកណ្តាល

៣៣-លោក ឡាំ - ប៊ុនថន ប្រធានការិយាល័យសុខាភិបាលស្រុកអង្គស្នួល ខេត្តកណ្តាល

៣៤ លោក ម៉ៅ ស្រៀង អនុប្រធានការិយាល័យសុខាភិបាលស្រុកអង្គស្នួល ខេត្តកណ្តាល

៣៥ លោក ហួត ថារ៉េត ប្រធានការិយាល័យសិរីយោដី និង ភូមិបាល ស្រុកអង្គស្នួលខេត្តកណ្តាល

៣៦ លោក ម៉ិះ - សុខុម គ្រូវិទ្យាល័យ ហ៊ុន សែន អង្គស្នួល

៣៧ លោក គុប មិត ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលជនពិការ ស្រុកអង្គស្នួល ខេត្តកណ្តាល

៣៨-លោក ភួន ផា មន្ត្រីការិយាល័យកសិកម្មស្រុកអង្គស្នួល ខេត្តកណ្តាល

៣៩-លោក មាស សារិន នាយកសាលាបឋមសិក្សាមង្គលបុរីស្រុកអង្គស្នួលខេត្តកណ្តាល

គ-មេដាយសេវ័ន្តការងារ :

១-លោក ចុក រិន អនុប្រធានមន្ទីរសង្គមកិច្ចការងារខេត្តកណ្តាល

២-លោក គង់ គីមជី ប្រធានការិយាល័យការងារមន្ទីរសង្គមកិច្ចខេត្តកណ្តាល

៣-លោក សំ - កុសល អនុប្រធានការិយាល័យការងារមន្ទីរសង្គមកិច្ចខេត្តកណ្តាល

៤-លោក ហេង- ទូច អនុប្រធានសង្គមកិច្ចការងារខេត្តកណ្តាល

៥-លោក សាត- សុទ្ធី អនុប្រធានការិយាល័យសុខមាលភាពខេត្តកណ្តាល

៦-លោក ព្រំ វណ្ណៈ អនុប្រធានមន្ទីរសង្គមកិច្ចការងារខេត្តកណ្តាល

៧-លោក គីម សារ៉ា ប្រធានការិយាល័យសង្គមកិច្ចខេត្តកណ្តាល

៨ លោកស្រី ស្វាយថុល មុនារិទ្ធ ប្រធានការិយាល័យសង្គមកិច្ចខេត្តកណ្តាល

៩-លោកស្រីពេញ-ណារ៉ុម ប្រធានការិយាល័យកិច្ចការនារីនិងអតីតយុទ្ធជនស្រុកអង្គស្នួលខេត្តកណ្តាល

១០-លោក ស័យ - សុខុន មន្ត្រីការិយាល័យ ប្រៃសណីយ៍ស្រុកអង្គស្នួល ខេត្តកណ្តាល

១១-លោក ចាប - វន្ថា មន្ត្រីការិយាល័យសាធារណៈការស្រុកអង្គស្នួល ខេត្តកណ្តាល

១២-លោក ផាន់ - ផាន គ្រូសាលាបឋមសិក្សាឈូកក្រពំស្រុកអង្គស្នួល ខេត្តកណ្តាល

១៣ លោក អ៊ូ សាវីន គ្រូវិទ្យាល័យ ហ៊ុន សែន អង្គស្នួល

១៤ លោក ឡឹក- សំអាង គ្រូអនុវិទ្យាល័យបែកចានស្រុកអង្គស្នួល ខេត្តកណ្តាល

១៥-លោក អ៊ុំ ឡាក់ មន្ត្រីការិយាល័យកសិកម្មស្រុកអង្គស្នួល ខេត្តកណ្តាល

១៦-លោក ឱ លឹម ប្រធានពន្ធដារស្រុកអង្គស្នួល ខេត្តកណ្តាល

១៧-លោក យឹម - លន អនុប្រធានការិយាល័យអប់រំស្រុកអង្គស្នួល ខេត្តកណ្តាល

១៨-លោក មៀច បិណ្ឌាត មន្ត្រីការិយាល័យសុខាភិបាលស្រុកអង្គស្នួល ខេត្តកណ្តាល

១៩-លោក នៅ បូណាត នាយសាលាបឋមសិក្សាទ្រទំជ្រើងស្រុកអង្គស្នួល ខេត្តកណ្តាល

២០-លោក សខ គង្គា នាយករងអនុវិទ្យាល័យប៊ឹងធំស្រុកអង្គស្នួល ខេត្តកណ្តាល

២១-លោក ឡុង - ឡាង នាយករងសាលាបឋមសិក្សា ឱង្គារស្រុកអង្គស្នួល ខេត្តកណ្តាល

២២ លោក អ៊ុក - យ៉ាន នាយកសាលាបឋមសិក្សា ឱង្គារស្រុកអង្គស្នួល ខេត្តកណ្តាល

២៣-លោក ឯក - ស្រ៊ុន	គ្រូបង្រៀនបឋមសិក្សា កុយតីបស្រុកអង្គស្នួល ខេត្តកណ្តាល
២៤-លោក នៅ - សារិ	នាយករងសាលាបឋមសិក្សាកុយតីបស្រុកអង្គស្នួលខេត្តកណ្តាល
២៥ លោក សោម- សារិ	គ្រូបង្រៀនបឋមសិក្សា អូជីបស្រុកអង្គស្នួល ខេត្តកណ្តាល
២៦-លោក ណុប - កនតាល់	គ្រូបង្រៀនបឋមសិក្សា ស្ទួនពេជ្រស្រុកអង្គស្នួល ខេត្តកណ្តាល
២៧ លោក កែ ប៊ុន	មន្ត្រីការិយាល័យអប់រំយុវជន និងកីឡាស្រុកអង្គស្នួលខេត្តកណ្តាល
២៨-លោកស្រី ទូច អាត	នាយិកាសាលាបឋមសិក្សា ព្រៃពួចស្រុកអង្គស្នួល ខេត្តកណ្តាល
២៩-លោក សៀង- ស៊ីម	មន្ត្រីសាលាស្រុកអង្គស្នួល ខេត្តកណ្តាល
៣០-លោក ស៊ុយ - សន	គ្រូសាលាបឋមសិក្សា ថ្នល់ទទឹងស្រុកអង្គស្នួល ខេត្តកណ្តាល
៣១ លោក ហែម- វ៉ុន	មន្ត្រីការិយាល័យអប់រំយុវជន និង កីឡាស្រុកអង្គស្នួល ខេត្តកណ្តាល
៣២ លោក នុត នុន	គ្រូអនុវិទ្យាល័យត្រពាំងត្នោតស្រុកអង្គស្នួល ខេត្តកណ្តាល
៣៣-លោក គង់ - យន់	គ្រូបង្រៀនសាលាបឋមសិក្សា តាប្រាបស្រុកអង្គស្នួល ខេត្តកណ្តាល
៣៤-លោក ឡាំ - សារឿន	នាយកសាលាបឋមសិក្សា ពោធិវង្គ័ស្រុកអង្គស្នួល ខេត្តកណ្តាល
៣៥ លោក ស៊ីរិត កើន	បុគ្គលិកពេទ្យឃុំ បឹងធំស្រុកអង្គស្នួល ខេត្តកណ្តាល
៣៦ លោក នត សម្បត្តិ	បុគ្គលិកពេទ្យឃុំបឹងធំស្រុកអង្គស្នួល ខេត្តកណ្តាល
៣៧-លោក នូ - សាខន	នាយករងអនុវិទ្យាល័យ បែកចានស្រុកអង្គស្នួល ខេត្តកណ្តាល
៣៨-លោក ហុង -គីមលៀង	នាយករងអនុវិទ្យាល័យ បែកចានស្រុកអង្គស្នួល ខេត្តកណ្តាល
៣៩ លោក មៀច សឿង	មន្ត្រីសាលាស្រុកអង្គស្នួលស្រុកអង្គស្នួល ខេត្តកណ្តាល
៤០ លោក សេង សំណាង	នាយកសាលាបឋមសិក្សា ទានអរស្រុកអង្គស្នួល ខេត្តកណ្តាល
៤១ លោក ម៉ែន ញ៉ិល	គ្រូសាលាបឋមសិក្សា បឹងប្រីយ៍ស្រុកអង្គស្នួល ខេត្តកណ្តាល
៤២-លោក ទេត - គុងហាក់	នាយកសាលាបឋមសិក្សា បឹងប្រីយ៍ស្រុកអង្គស្នួល ខេត្តកណ្តាល
៤៣-លោក ម៉ិន - ហាក់	គ្រូសាលាបឋមសិក្សា ត្នោតខ្ពស់ស្រុកអង្គស្នួល ខេត្តកណ្តាល
៤៤ លោក ទន់ - សុជាតិ	នាយកសាលាបឋមសិក្សា អង្គស្តុកស្រុកអង្គស្នួល ខេត្តកណ្តាល
៤៥ លោក យឹម អ៊ីម	មន្ត្រីការិយាល័យវប្បធម៌និងវិចិត្រសិល្បៈស្រុកអង្គស្នួលខេត្តកណ្តាល
៤៦-លោកស្រី ហែម-ស៊ីនឿន	នាយិកាសាលាបឋមសិក្សា អង្គពាយស្រុកអង្គស្នួល ខេត្តកណ្តាល

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា១ និង មាត្រា២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា១. -

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម ឧត្តមសេនីយ៍ **រីយ៉ាមីហ្សាដ រីយ៉ាគូឌូ** នាយសេនាធិការកងទ័ពជើងគោក ឥណ្ឌូនេស៊ី (*General RYAMIZARD RYACUDU Chief of Staff of Indonesian National Army*) ដែលមានគុណបំណាច់ និង ស្នាដៃល្អក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការ រវាងកងទ័ព នៃប្រទេសទាំងពីរ កម្ពុជា ឥណ្ឌូនេស៊ី ។

មាត្រា២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៤៥ . អនក្រ តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ
ជាកិច្ចបច្ចាមរណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ចាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ទោ **ឡឹក សំអាត** អត្តលេខ ០៤១៩ ស្នងការរង និងជាប្រធានការិយាល័យកណ្តាលសន្តិសុខ នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- កាលប្បវត្តិ ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

សម្រេច

មាត្រា១. -

ត្រូវបានចំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១០គ្រឿង ជូនអង្គការអន្តរជាតិ និងមន្ត្រីសំរបសំរួល ដែលបានធ្វើសហប្រតិបត្តិការ ជួយកសាង និង អភិវឌ្ឍន៍ វិស័យសង្គមកិច្ច នៅខេត្តបាត់ដំបង ដោយចំណាយអស់ទឹកប្រាក់ជំនួយ សរុបចំនួន ៤៩៩.៩៥១.៦៤ ដុល្លារ ដូចមានខាងក្រោម :

ក.មេដាយមាសស្ថាបនាជាតិ :

១ អង្គការ	UNICEF	បាត់ដំបង
២-អង្គការ	HI	បាត់ដំបង
៣-អង្គការ	ICRC	បាត់ដំបង
៤ អង្គការ	WVI	បាត់ដំបង
៥-លោក	**ងួន ជា**	មន្ត្រីសំរបសំរួល កម្មវិធីជាមួយ អង្គការ UNICEF
៦-លោក	**ឃុន ឫទ្ធី**	មន្ត្រីសំរបសំរួល កម្មវិធីជាមួយ អង្គការ H.I
៧-លោក	**គង់ ស្រ៊ុន**	មន្ត្រីសំរបសំរួល អង្គការ UNICEF

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១ លោក **យ៉ាន អ៊ីះ** មន្ត្រីសំរបសំរួល កម្មវិធី សមាហរណកម្ម

២ លោក **សា ឡើន** មន្ត្រីសំរបសំរួល កម្មវិធី **PCPC**

គ.មេដាយសំរិទ្ធស្ថាបនាជាតិ :

-លោក **ចំរេម គីមឃួ** មន្ត្រីសំរបសំរួល កម្មវិធី **CBCP**

មាត្រា២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនិតិ សម្បទា និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ចំនួន ០១គ្រឿង ជូនលោកវរសេនីយ៍ឯក **ហ្សាក់ អ៊ិស្ណារ៉ៈ** *(Colonel Jacques ISNARD)* សេនាទូត នៃ សាធារណរដ្ឋ បារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញភារកិច្ច រយៈពេល០៣ឆ្នាំ នៅកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ. ៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួង មហាផ្ទៃ

សម្រេច

មាត្រា១.

